GMAC
Garment Manufacturers Association in Cambodia

# សេចក្តីប្រកាសព័ត៌មាន

## សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC)សំដែងការខកចិត្តចំពោះសហភាពអឺរ៉ុបបន្ទាប់ពីការព្យួរដោយផ្នែកនៃកម្មវិធី«អនុគ្រោះពន្ធលើគ្រប់មុខទំនិញលើកលែងតែគ្រឿងសព្វាវុធ»(EBA)សម្រាប់កម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០** – សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC)សោកស្តាយយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចប្រកាសនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់សហភាពអឺរ៉ុប ដែលព្យួរផ្នែកខ្លះនៃកម្មវិធី «អនុគ្រោះពន្ធលើគ្រប់មុខទំនិញលើកលែងតែគ្រឿងសព្វាវុធ»(EBA)សម្រាប់កម្ពុជា។

កម្មវិធីEBAអនុញ្ញាតឲ្យបណ្តាប្រទេសអឺរ៉ុបនាំចូលផលិតផលពីប្រទេសកម្ពុជា(លើកលែងតែគ្រឿងសព្វាវុធ) ដោយមិនយកពន្ធនិងគ្មានកូតា។ អ្នកទទួលបានអត្ថប្រយោជន៍សំខាន់ៗពីកម្មវិធីនេះគឺវិស័យកាត់ដេរ និងផលិតផលធ្វើដំណើររបស់កម្ពុជាដែលតំណាងដោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC)។ ឧស្សាហកម្មទាំងនេះមានចំនួនប្រមាណ ៧៥ភាគរយ នៃការនាំចេញទំនិញសរុបរបស់កម្ពុជា និងប្រមាណ៩០ភាគរយនៃការនាំចេញទៅសហភាពអឺរ៉ុបដែលជាទីផ្សារធំបំផុតសម្រាប់ទំនិញដែលផលិតដោយបណ្តារោងចក្រតំណាងដោយGMAC។

ការផ្តល់ការងារនៅក្នុងវិស័យទាំងនេះដែលគាំទ្រដោយកម្មវិធីអនុគ្រោះពន្ធEBA ឥឡូវនេះមានចំនួនលើស ៧៥០.០០០នាក់ និងបានរួមចំណែកដល់ការទាញប្រជាជនកម្ពុជារាប់លាននាក់ចេញពីភាពក្រីក្រ។ កម្មករភាគច្រើនបំផុតជាស្ត្រីដែលគ្រប់គ្រងគ្រួសារ មើលថែសុខភាព និងសុខុមាលភាពរបស់កូនៗ និងផ្តល់ប្រាក់ចំណូលដោយផ្ទាល់ដល់គ្រួសារជាង២០ភាគរយនៃគ្រួសារក្នុងប្រទេសកម្ពុជា។

សមាគមសូមជំរុញគណៈកម្មការអឺរ៉ុបនិងសមាជិកសភាអឺរ៉ុបពិចារណាឡើងវិញចំពោះសេចក្តីសម្រេចនេះ ដោយពិចារណាទៅលើគុណតម្លៃនៃកម្មវិធីនេះដែលត្រូវបានដាក់អនុវត្តជិត២០ឆ្នាំកន្លងទៅ: ជំនួយអភិវឌ្ឍន៍ ការកាត់បន្ថយភាពក្រីក្រ និងសេចក្តីថ្លៃថ្នូរនៃការងារ។ កម្មវិធីEBAគឺជាជោគជ័យច្បាស់មួយនៅក្នុងប្រទេសកម្ពុជាក្នុងការសម្រេចបាននូវគោលដៅទាំងនេះ។ ការដកដោយផ្នែកនៃកម្មវិធីនេះនឹងបានត្រឹមតែធ្វើឲ្យបាត់បង់ការងារនិងនាំឲ្យមានភាពក្រីក្រ។

ជាផ្នែកនៃការប្តេជ្ញាចិត្តទៅវិញទៅមករបស់យើងចំពោះកម្មវិធី EBA សមាគមបានបង្កើតវប្បធម៌តម្លាភាពនិងគណនេយ្យភាពនៅក្នុងផ្នែកអនុលោមភាពការងារនិងលក្ខខណ្ឌការងារ។ នៅក្នុងការស្គាល់ថាជា «កម្ពុជាគំរូ» សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) គឺជាសមាគមទីមួយមុនគេបំផុតក្នុងពិភពលោកដែលស្វាគមន៍អង្គការអន្តរជាតិខាងការងារ (ILO) របស់អង្គការសហប្រជាជាតិដើម្បីបង្កើតកម្មវិធីត្រួតពិនិត្យបណ្តារោងចក្ររបស់យើងសម្រាប់អនុលោមភាពទៅតាមលក្ខខណ្ឌតម្រូវថ្នាក់ជាតិនិងអន្តរជាតិ។ គ្មានវិស័យណាមួយនៅក្នុងប្រទេស



តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Phnom Penh Special Economic Zone, Trapeang Kul Village, Sangkat Kantouk, Khan Por Sen Chey, Phnom Penh Cambodia.
Tel: (855) 23-88 34 35 E-mail: info@gmac-cambodia.org Website: www.gmac-cambodia.org

ដទៃណាដែលទទួលបាននូវអត្ថប្រយោជន៍ពីការអនុគ្រោះពន្ធទៅទីផ្សារសហភាពអឺរ៉ុប មានកំណត់ត្រានៃកិច្ចសហប្រតិបត្តិការជាមួយ ILO ប្រសើរជាងកម្ពុជានោះទេ។

GMACក៏បានគាំទ្រប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលរបស់កម្ពុជាផងដែរ ព្រមទាំងនវានុវត្តន៍ដទៃៗទៀតនៅក្នុងវិស័យទំនាក់ទំនងវិជ្ជាជីវៈ ដែលបានគាំទ្រការអភិវឌ្ឍចលនាសហជីពរឹងមាំមួយនៅក្នុងវិស័យរបស់យើង។

GMACគោរពនិងគាំទ្រការចូលរួមរបស់សហភាពអឺរ៉ុបក្នុងការកែលម្អគោលនយោបាយសិទ្ធិមនុស្ស។ ជាអកុសល ការដកការជួយភ្លាមៗបែបនេះពីប្រជាពលរដ្ឋកម្ពុជារាប់សែននាក់មិនមែនជាវិធីដែលត្រូវបន្តទៅមុខនោះទេ។

សេចក្តីសម្រេចរបស់សហភាពអឺរ៉ុបនឹងទំនងជាធ្វើឲ្យមានការភាន់ច្រឡំពាក់ព័ន្ធនឹងស្ថានភាពពាណិជ្ជកម្មរបស់យើងដែលកំពុងឆ្ពោះទៅមុខ ហើយនឹងលើកទឹកចិត្តឲ្យអ្នកបញ្ជាទិញទៅទិញពីបណ្តាប្រទេសដទៃៗដែលមានការគោរពសិទ្ធិសហជីពអន់ថយជាងកម្ពុជា ហើយទំនងជាបណ្តាលឲ្យមានការបាត់បង់ការងារដល់កម្មកររាប់ម៉ឺននាក់ ហើយដែលភាគច្រើនបំផុតនៃពួកគេគឺជាសមាជិកសហជីព ហើយធ្វើឲ្យមានភាពក្រីក្រកាន់តែខ្លាំងឡើងនៅក្នុងប្រទេស ហើយធ្វើឲ្យវាកាន់តែលំបាកក្នុងការដំឡើងប្រាក់ឈ្នួល និងអត្ថប្រយោជន៍សម្រាប់កម្មករដោយសារផលប៉ះពាល់អវិជ្ជមាននៃភាពប្រកួតប្រជែងមកលើវិស័យរបស់យើង ដោយសារពន្ធដែលដាក់ដោយសហភាពអឺរ៉ុប។

សមាជិកGMACមានមោទនភាពចំពោះការរួមចំណែកដែលពួកគេបានធ្វើ ហើយនឹងបន្តធ្វើការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ យើងបានយល់ជាយូរមកហើយថា ការធ្វើឲ្យជីវិតរបស់មនុស្សម្នាក់ប្រសើរឡើងគឺចាប់ផ្តើមជាមួយនឹងការមានជំរំបូលផ្ទះ និងអាហារបរិភោគ។

សមាគមសូមជំរុញសហភាពអឺរ៉ុបផ្តល់អត្ថប្រយោជន៍EBAដូចដើមវិញសម្រាប់វិស័យរបស់យើងដើម្បីបុព្វហេតុនៃការអភិវឌ្ឍប្រកបដោយចីរភាព និងប្រជាជនកម្ពុជារាប់សែននាក់ដែលបានទទួលអត្ថប្រយោជន៍ពីកម្មវិធីEBAដើម្បីចាកចេញពីភាពក្រីក្រ លើកកម្ពស់សិទ្ធិរបស់ពួកគេនៅកន្លែងការងារ និងផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។

**អំពីGMAC៖**

GMACតំណាងឲ្យរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរជាង៥៨០រោងចក្រក្នុងប្រទេសកម្ពុជាដែលបានផ្តល់ការងារដល់កម្មករចំនួន៧៥០,០០០នាក់។ បេសកកម្មរបស់យើងគឺធ្វើឲ្យកម្ពុជាក្លាយជាដៃគូជាទីពេញចិត្តនៅក្នុងទីផ្សារសកល ដែលមានលក្ខណៈប្រកួតប្រជែងខ្លាំងដោយប្រកាន់ខ្ជាប់នូវស្តង់ដារខ្ពស់បំផុតចំពោះគុណភាពទំនិញ និងគុណភាពជីវិតរបស់កម្មកររបស់យើង។

គេហទំព័រ៖ https://www.gmac-cambodia.org/

ទំនាក់ទំនងសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ៖ លោក ខេន លូ
លេខទូរស័ព្ទ៖ +855 12 282 288
អ៊ីម៉ែល៖ kenloo@gmac-cambodia.org

ព្រះរាជាណាចក្រកម្ពុជា
GARMENT MANUFACTURERS ASSOCIATION IN CAMBODIA
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា